មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៨-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧៦៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះថ្នាក់ដឹកនាំក្រសួងបរិស្ថាន ចំនួន ០៣ រូប ៦៤២៥

២៨-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧៦៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ប្រគេនព្រះតេជគុណ ម៉ែន ហម ព្រះគ្រូចៅអធិការវត្តទ័ពចំបក់មាស សង្កាត់ទឿន ខណ្ឌដង្កោ រាជធានីភ្នំពេញ ៦៤២៦

២៨-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧៦៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ នាយនគរបាលជាតិជាន់ខ្ពស់ ចំនួន ១១៣ រូប នៃក្រសួងមហាផ្ទៃ ៦៤២៧

២៨-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧៦៧ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ជូននាយនគរបាលជាតិជាន់ខ្ពស់ ចំនួន ០៥ រូប នៃក្រសួងមហាផ្ទៃ ៦៤៣២

២៨-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧៦៨ ស្តីពី ការតែងតាំង លោក គុយ សុខខន់ ជា ឧកញ៉ា ៦៤៣៣

២៩-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧៦៩ ស្តីពី ការប្រោសព្រះរាជទាន ចំពោះឯកឧត្តម មុត ខៀវ នូវគ្រឿងឥស្សរិយយស ជាតូបការ ៦៤៣៤

២៩-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧៧០ ស្តីពី ការតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ទោ ធឹម សុផា នាយនគរបាលជាតិជាន់ខ្ពស់ ជាទីប្រឹក្សា ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន និង ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយឯក ជូនលោកឧត្តមសេនីយ៍ទោ ធឹម សុផា នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៦៤៣៥

២៩-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧៧១ ស្តីពី ការដំឡើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ទោ ជូនលោកឧត្តមសេនីយ៍ត្រី យស់ ផន នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៦៤៣៦

២៩-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧៧៥ ស្តីពី ការដំឡើងឋានៈឯកឧត្តមអគ្គលេខាធិការរងរាជរដ្ឋាភិបាល ចំនួន ០២ រូប មានឋានៈ ស្មើ រដ្ឋលេខាធិការ ៦៤៣៧

២៩-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧៧៨ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ និង សប្បុរសជន ចំនួន ២៨ រូប ៦៤៣៨

II-រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

០៤-៩-២០១២ -អនុក្រឹត្យលេខ ១៣៦ អនក្រ.បក ស្ដីពី ការកែសម្រួលគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា ៦៤៣៩

០៥-៩-២០១២ -អនុក្រឹត្យលេខ ១៣៧ អនក្រ.បក ស្ដីពី ការផ្ទេរឥណទានថវិកា ៦៤៤៨

០៦-៩-២០១២ -អនុក្រឹត្យលេខ ១៣៨ អនក្រ.បក ស្ដីពី ការទទួលស្គាល់ការប្រែក្លាយពី វិទ្យាស្ថាន ប៊ែលធី អន្តរជាតិ ទៅជា សាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ ៦៤៥០

០៦-៩-២០១២ -អនុក្រឹត្យលេខ ១៣៩ អនក្រ.បក ស្ដីពី ការកែសម្រួលមាត្រា ៤ និង មាត្រា ១៣ នៃអនុក្រឹត្យលេខ ១២១ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៩ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំង រក្សាសន្តិភាព បោសសំអាតមីន និង កាកសំណល់សង្គ្រាម ៦៤៥៣

០៤-៩-២០១២ -អនុក្រឹត្យលេខ ១០៥៣ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៦៤៥៦

០៤-៩-២០១២ -អនុក្រឹត្យលេខ ១០៥៤ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៦៤៥៧

០៤-៩-២០១២ -អនុក្រឹត្យលេខ ១០៥៥ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៦៤៥៨

០៤-៩-២០១២ -អនុក្រឹត្យលេខ ១០៥៦ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៦៤៥៩

០៤-៩-២០១២ -អនុក្រឹត្យលេខ ១០៥៧ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៦៤៦០

០៤-៩-២០១២ -អនុក្រឹត្យលេខ ១០៥៨ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៦៤៦១

០៤-៩-២០១២ -អនុក្រឹត្យលេខ ១០៥៩ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៦៤៦២

០៤-៩-២០១២ -អនុក្រឹត្យលេខ ១០៦០ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៦៤៦៣

០៤-៩-២០១២ -អនុក្រឹត្យលេខ ១០៦១ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៦៤៦៤

០៤-៩-២០១២ -អនុក្រឹត្យលេខ ១០៦២ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៦៤៦៥

០៤-៩-២០១២ -អនុក្រឹត្យលេខ ១០៦៣ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៦៤៦៦

០៤-៩-២០១២ -អនុក្រឹត្យលេខ ១០៦៤ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៦៤៦៧

០៤-៩-២០១២ -អនុក្រឹត្យលេខ ១០៦៥ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៦៤៦៨

០៤-៩-២០១២ -អនុក្រឹត្យលេខ ១០៦៦ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៦៤៦៩

០៤-៩-២០១២ -អនុក្រឹត្យលេខ ១០៦៧ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៦៤៧០

០៤-៩-២០១២ -អនុក្រឹត្យលេខ ១០៦៨ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៦៤៧១

០៤-៩-២០១២ -អនុក្រឹត្យលេខ ១០៦៩ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៦៤៧២

០៤-៩-២០១២ -អនុក្រឹត្យលេខ ១០៧០ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៦៤៧៣
០៤-៩-២០១២ -អនុក្រឹត្យលេខ ១០៧១ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៦៤៧៤
០៤-៩-២០១២ -អនុក្រឹត្យលេខ ១០៧២ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៦៤៧៥
០៤-៩-២០១២ -អនុក្រឹត្យលេខ ១០៧៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៦៤៧៦
០៤-៩-២០១២ -អនុក្រឹត្យលេខ ១០៧៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៦៤៧៧
០៤-៩-២០១២ -អនុក្រឹត្យលេខ ១០៧៥ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៦៤៩៨

២_សេចក្តីសំរេច

០៣-៩-២០១២ -សេចក្តីសំរេចលេខ ៣៤ សសរ ស្តីពី ការបង្កើតគណៈកម្មការរៀបចំពិធីបុណ្យសមុទ្រ ថ្ងៃទី ២៩-៣១ ខែធ្នូ ឆ្នាំ ២០១២ នៅខេត្តកែប ក្រោមប្រធានបទ " ផ្ទៃសមុទ្រពណ៌ខៀវស្រងាត់ ទីក្រុងបៃតង " ៦៥១៦
០៦-៩-២០១២ -សេចក្តីសំរេចលេខ ៣៥ សសរ ស្តីពី ការកែសម្រួលសេចក្តីសម្រេចស្តីពី ការតែងតាំងតំណាងជាតិសម្រាប់ក្រុមប្រឹក្សាសហគមន៍នយោបាយ - សន្តិសុខអាស៊ាន ក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ាន និង ក្រុមប្រឹក្សាសហគមន៍-វប្បធម៌អាស៊ាន ៦៥២២

III_ការងារបណ្តាក្រសួង

ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៥-៥-២០១១ -លិខិតបញ្ជាក់លេខ ២៤៦៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន 338 **ប្រឌីធី** ៦៥២៤
០៥-៥-២០១១ -លិខិតបញ្ជាក់លេខ ២៤៦៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៊ី.ធី.ប៊ី. សឹគសេស** ៦៥២៦
០៥-៥-២០១១ -លិខិតបញ្ជាក់លេខ ២៤៧០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិល.ត៊ី.អេស.អេ ស៊ីឃ្យូរីធី** ៦៥២៨
០៦-៥-២០១១ -លិខិតបញ្ជាក់លេខ ២៤៧៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជី ស៊ី អ៊ែរ ខិនឌីសិននីង** ៦៥៣០
០៦-៥-២០១១ -លិខិតបញ្ជាក់លេខ ២៤៨៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៊ី អេច អិល អ៊ីមផត អិចផត** ៦៥៣២
០៦-៥-២០១១ -លិខិតបញ្ជាក់លេខ ២៤៨៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខមហ្សូន (ខេមបូឌា)** ៦៥៣៤

០៦-៥-២០១១ -លិខិតបញ្ជាក់លេខ ២៤៨៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជីង ចូវ ហាយ យ៉ន (ខេមបូឌា) អេឡិគទ្រិក ផៅវ័រ អេឃ្វីបមេន** ៦៥៣៦

០៦-៥-២០១១ -លិខិតបញ្ជាក់លេខ ២៤៩២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **បាហ្គាឌ៉ា ខឹមម៉ឌិធី** ៦៥៣៨

០៦-៥-២០១១ -លិខិតបញ្ជាក់លេខ ២៤៩៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដាប់ប៉ែលយូ ដាប់ប៉ែលយូ អជី (ខេមបូឌា)** ៦៥៤០

០៦-៥-២០១១ -លិខិតបញ្ជាក់លេខ ២៤៩៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស ស៊ី ខេ អ៊ិនធើណេសិនណល គ្រុប** ៦៥៤២

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧៦៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំក្រសួងបរិស្ថាន ចំនួន ០៣រូប ដែលមានស្នាដៃល្អ និងគុណបំណាច់ធំៗជាច្រើន
ក្នុងការចូលរួមចំណែកកសាងអភិវឌ្ឍន៍ប្រទេសជាតិ ស្របតាមគោលនយោបាយ
របស់រាជរដ្ឋាភិបាល ស្តីពីកិច្ចការពារបរិស្ថាន និងអភិរក្សធនធានធម្មជាតិ
នៃព្រះរាជាណាចក្រកម្ពុជា

នូវ

គ្រឿងឥស្សរិយយស **ជាតូបការ** :

- ឯកឧត្តម **ខៀវ មុត**
- ឯកឧត្តម **យិន គឹមស៊ាន**
- ឯកឧត្តម **ឌឹត គ្រឿនខុន្តា**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រសា.១២០៥.៧៣៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១២

លេខ ៧៣៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ២០១២
[illegible]រាជរដ្ឋាភិបាល

ស៊យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧៦៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ប្រគេន

ព្រះតេជគុណ ម៉ែន ហម

ព្រះគ្រូចៅអធិការវត្តទំពចំបក់មាស ដែលមានព្រះគុណបំណាច់ចំពោះជាតិ និងសាសនា
ដោយបានបរិច្ចាគបច្ច័យចូលរួមជួយកសាងសមិទ្ធផលនានា ក្នុងវិស័យព្រះពុទ្ធសាសនា
នៅក្នុងវត្តទំពចំបក់មាស សង្កាត់ទៀន ខណ្ឌដង្កោ រាជធានីភ្នំពេញ

ព្រះហស្តលេខា និងព្រះរាជលញ្ចករ
នរោត្តម សីហមុនី

ចរសេ. ១២០៤.៧៧២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១២

លេខ: ៧៣៩០ ច.ល
ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្ដីការរដ្ឋាភិបាល
សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧៦៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

នាយនគរបាលជាតិជាន់ខ្ពស់ចំនួន ១១៣ រូប នៃក្រសួងមហាផ្ទៃ ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចថែរក្សា ការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងស្ថេរភាពសង្គម ដើម្បីបំរើផលប្រយោជន៍របស់ប្រទេសជាតិ និងប្រជាពលរដ្ឋបានល្អប្រសើរ

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ៖

១- លោកឧត្តមសេនីយ៍ទោ សេង វណ្ណា អត្តលេខ ០៣៩២
២- លោកឧត្តមសេនីយ៍ទោ ឆាយ គឹមខឿន អត្តលេខ ០៦៧៧

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ៖

១- លោកស្រីឧត្តមសេនីយ៍ឯក យក់ សុខា អត្តលេខ ០២២៥៨
២- លោកឧត្តមសេនីយ៍ទោ យឹម ស៊ីមុនី អត្តលេខ ០៣៦២៧
៣- លោកឧត្តមសេនីយ៍ទោ តាន់ ចាយ អត្តលេខ ០៤០៨
៤- លោកឧត្តមសេនីយ៍ត្រី ជ័យ ឫទ្ធី អត្តលេខ ០៦៤១
៥- លោកឧត្តមសេនីយ៍ត្រី ជា សុជាត អត្តលេខ ០៥៣៤
៦- លោកឧត្តមសេនីយ៍ត្រី ស៊ុន វុឌ្ឍី អត្តលេខ ០៦៤៩
៧- លោកឧត្តមសេនីយ៍ត្រី ចាប់ សារិទ្ធ អត្តលេខ ០៥៣៧
៨- លោកឧត្តមសេនីយ៍ត្រី សូ ប៊ុននឿន អត្តលេខ ០៤២៥
៩- លោកឧត្តមសេនីយ៍ត្រី អៀង សាមីន អត្តលេខ ០២៥៧
១០- លោកឧត្តមសេនីយ៍ត្រី សូ វ៉ាន់ទិ អត្តលេខ ០២៣០៤
១១- លោកឧត្តមសេនីយ៍ត្រី គិន ឡាយ អត្តលេខ ០៦២១
១២- លោកឧត្តមសេនីយ៍ត្រី យី សាមឿន អត្តលេខ ០៦៨០

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

១៣- លោកឧត្តមសេនីយ៍ត្រី	ខ្លូត	វុន	អត្តលេខ ០៥២១៧
១៤- លោកឧត្តមសេនីយ៍ត្រី	ង៉ិល	វណ្ណធឿន	អត្តលេខ ០១០២៧
១៥- លោកឧត្តមសេនីយ៍ត្រី	ម៉ៅ	និម្មល	អត្តលេខ ០២០០
១៦- លោកឧត្តមសេនីយ៍ត្រី	គាន	ទ្រី	អត្តលេខ ០៥៤៩
១៧- លោកវរសេនីយ៍ឯក	អ៊ូ	ចាន់កុសល	អត្តលេខ ០៥០១១
១៨- លោកវរសេនីយ៍ឯក	សុខ	សុផាត	អត្តលេខ ០១៧៤៣
១៩- លោកវរសេនីយ៍ឯក	យ៉ែ	ធឿន	អត្តលេខ ៥៦០៣៤
២០- លោកវរសេនីយ៍ឯក	ទូច	ពលៈ	អត្តលេខ ១២៣០៥
២១- លោកវរសេនីយ៍ឯក	ជៀវ	សូរិយា	អត្តលេខ ០៤៨៧

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ៖

១- លោកឧត្តមសេនីយ៍ទោ	ខឹម	កាន	អត្តលេខ ០២១៣
២- លោកឧត្តមសេនីយ៍ត្រី	មុន្នី	រតនា	អត្តលេខ ០២៧០
៣- លោកឧត្តមសេនីយ៍ត្រី	គី	ដារ៉ា	អត្តលេខ ០៥៤៧
៤- លោកស្រីឧត្តមសេនីយ៍ត្រី	សុខ	ចន្ធីរ៉ា	អត្តលេខ ០២២២៥
៥- លោកឧត្តមសេនីយ៍ត្រី	យ៉ុង	សំខាន់	អត្តលេខ ០១៦៧៣
៦- លោកឧត្តមសេនីយ៍ត្រី	សិទ្ធិ	ប៊ុនធី	អត្តលេខ ០១១៧៧
៧- លោកឧត្តមសេនីយ៍ត្រី	នូ	សារ៉ារិទ្ធ	អត្តលេខ ០៧៦០
៨- លោកឧត្តមសេនីយ៍ត្រី	ឡុង	យឿន	អត្តលេខ ០១២៧៤
៩- លោកឧត្តមសេនីយ៍ត្រី	ឆាយ	គឹមសុន	អត្តលេខ ០៥០២
១០- លោកវរសេនីយ៍ឯក	អាន	ស្រៀង	អត្តលេខ ១៦៦២៧
១១- លោកវរសេនីយ៍ឯក	ប៉ែន	ដារី	អត្តលេខ ១២៩៩២
១២- លោកវរសេនីយ៍ឯក	ណុប	រី	អត្តលេខ ០៩៤៤
១៣- លោកវរសេនីយ៍ឯក	ឈុន	ចាន់ថន	អត្តលេខ ០៩១៩
១៤- លោកវរសេនីយ៍ឯក	ហាវ	ចាន់សិទ្ធី	អត្តលេខ ៦៦៧៨
១៥- លោកវរសេនីយ៍ឯក	ចាន់	ស៊ីផុន	អត្តលេខ ០៤៣០
១៦- លោកវរសេនីយ៍ឯក	អេង	ហៀង	អត្តលេខ ០៥០៣
១៧- លោកវរសេនីយ៍ឯក	ចេន	ចាន់ថន	អត្តលេខ ០១៧៥៤
១៨- លោកវរសេនីយ៍ឯក	ប៊ុម	ប៊ិន	អត្តលេខ ០១៧៤៤
១៩- លោកវរសេនីយ៍ឯក	បួន	ចាប់ជាប់	អត្តលេខ ០១៧៣២
២០- លោកវរសេនីយ៍ឯក	ហេង	សម្បត្តិ	អត្តលេខ ០៣២៣៥
២១- លោកវរសេនីយ៍ឯក	កុំន្ទ	សម្បត្តិ	អត្តលេខ ០៤៥៦
២២- លោកវរសេនីយ៍ឯក	ឡាច	សារិន	អត្តលេខ ០៤៩២

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

២៣- លោកវរសេនីយ៍ឯក	ញ៉ឹក	កែវ	អត្តលេខ ០៤៩៣
២៤- លោកវរសេនីយ៍ឯក	ស៊ាង	កសល	អតលេខ ០៤២៧
២៥- លោកវរសេនីយ៍ឯក	យិន	ប៊ុនណាត	អត្តលេខ ០៤២៦
២៦- លោកវរសេនីយ៍ឯក	ជិន	វិទ្យា	អត្តលេខ ០២៥៩២
២៧- លោកវរសេនីយ៍ឯក	ម៉ាត្រ	សូត្រ	អត្តលេខ ១៦២០២
២៨- លោកវរសេនីយ៍ឯក	ជរ	ហេង	អត្តលេខ ០១៩៨៦
២៩- លោកវរសេនីយ៍ឯក	បាន	ហេង	អត្តលេខ ០១៦១៤
៣០- លោកវរសេនីយ៍ទោ	ជាម	សុខា	អត្តលេខ ១២៩៧៦

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ៖

១- លោកឧត្តមសេនីយ៍ត្រី	គឹម	ង៉ែតសុពល	អត្តលេខ ០២៦៧
២- លោកឧត្តមសេនីយ៍ត្រី	យ៉ែម	ម៉ៅ	អត្តលេខ ០២៦៨
៣- លោកឧត្តមសេនីយ៍ត្រី	ឌុច	ឌឿន	អត្តលេខ ០២៦៩
៤- លោកឧត្តមសេនីយ៍ត្រី	អ៊ុក	វណ្ណា	អត្តលេខ ០១០០៦
៥- លោកឧត្តមសេនីយ៍ត្រី	អោម	សារ៉ែន	អត្តលេខ ០២២៧៨
៦- លោកឧត្តមសេនីយ៍ត្រី	នួន	ថាន	អត្តលេខ ០៩៧៩
៧- លោកឧត្តមសេនីយ៍ត្រី	ម៉ៅ	សំបុណ្យ	អត្តលេខ ០៣០៧៥
៨- លោកវរសេនីយ៍ឯក	ចាន់	វុទ្ធី	អត្តលេខ ០៩៧២
៩- លោកវរសេនីយ៍ឯក	សេង	ជា	អត្តលេខ ០៩៣៧
១០- លោកវរសេនីយ៍ឯក	កៅ	ប៊ុនសុង	អត្តលេខ ១១១១
១១- លោកវរសេនីយ៍ឯក	ស្មាន់	សាវៀន	អត្តលេខ ២២២៣
១២- លោកវរសេនីយ៍ឯក	ឈឹម	ថន	អត្តលេខ ០៩១៦
១៣- លោកស្រីវរសេនីយ៍ឯក	លឹម	សុវណ្ណា	អត្តលេខ ០៤៤៥៦
១៤- លោកវរសេនីយ៍ឯក	ជឹម	សេងហុង	អត្តលេខ ០១៧៥០
១៥- លោកវរសេនីយ៍ឯក	កុល	ផាលី	អត្តលេខ ០១៩៨០
១៦- លោកវរសេនីយ៍ឯក	រស់	សាមឹ	អត្តលេខ ០៧៥៥៩
១៧- លោកវរសេនីយ៍ទោ	សោម	បាកាន	អត្តលេខ ០១៥៣០
១៨- លោកវរសេនីយ៍ទោ	លឹម	ហេងលាង	អត្តលេខ ០៥៥៤៥

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ៖

១- លោកវរសេនីយ៍ឯក	យិន	យឿន	អត្តលេខ ០៧០៧
២- លោកវរសេនីយ៍ឯក	វ៉ាន់	សុគន្ធ	អត្តលេខ ០៧០៨
៣- លោកវរសេនីយ៍ឯក	លួ	ប៉ាបូ	អត្តលេខ ៥៦០២៦

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៤- លោកស្រីវរសេនីយ៍ឯក	ហួត	យ៉ាន	អត្តលេខ ០៥៤៤១
៥- លោកវរសេនីយ៍ឯក	ធុច	ខេមរិទ្ធ	អត្តលេខ ០៣៩៩៨
៦- លោកវរសេនីយ៍ឯក	ចាន់	សារី	អត្តលេខ ០១០៣៧
៧- លោកវរសេនីយ៍ឯក	ហួរ	សាឌី	អត្តលេខ ០១០២៩
៨- លោកវរសេនីយ៍ឯក	អ៊ឹម	វិសាន	អត្តលេខ ០១០៣១
៩- លោកវរសេនីយ៍ឯក	លឹម	ដារុធ	អត្តលេខ ០៣៥១៨
១០- លោកវរសេនីយ៍ឯក	ប៊ុន	រ៉ា	អត្តលេខ ៣២៣២៣
១១- លោកវរសេនីយ៍ឯក	ស៊ូ	ម៉ាក់ឌី	អត្តលេខ ០៣១០៥
១២- លោកវរសេនីយ៍ឯក	អោម	ភិរម្យ	អត្តលេខ ១១៨៩១
១៣- លោកវរសេនីយ៍ឯក	សោម	សុគន្ធ	អត្តលេខ ១១៨៨៦
១៤- លោកវរសេនីយ៍ឯក	ហេង	សំផុន	អត្តលេខ ០១៣១៨
១៥- លោកវរសេនីយ៍ឯក	សុខ	មិន	អត្តលេខ ០៥២៧១
១៦- លោកវរសេនីយ៍ឯក	ឌួង	គឹមសាន្ត	អត្តលេខ ០៧០៩
១៧- លោកវរសេនីយ៍ឯក	អ៊ូ	សំនៀង	អត្តលេខ ០៧១០
១៨- លោកវរសេនីយ៍ឯក	ធិប	ហួរ	អត្តលេខ ០២២៩៥
១៩- លោកវរសេនីយ៍ឯក	សាង	វុទ្ធី	អត្តលេខ ០៥០៣៩
២០- លោកវរសេនីយ៍ឯក	ស៊ិន	សៀក	អត្តលេខ ០៣៣១១
២១- លោកវរសេនីយ៍ឯក	ឈន	បូរី	អត្តលេខ ០៥៦៩២
២២- លោកវរសេនីយ៍ឯក	ប៉ាង	ណារិទ្ធ	អត្តលេខ ០១០០៥
២៣- លោកវរសេនីយ៍ឯក	អៀម	ប៊ុនឈឿន	អត្តលេខ ០៦៦៨
២៤- លោកវរសេនីយ៍ឯក	នៅ	សុវណ្ណារិទ្ធ	អត្តលេខ ០១០១៥
២៥- លោកវរសេនីយ៍ឯក	ចាន់	ផល្លា	អត្តលេខ ០៨៨១
២៦- លោកវរសេនីយ៍ឯក	ឆាយ	ម៉ៅ	អត្តលេខ ០១១៣៣
២៧- លោកវរសេនីយ៍ឯក	លុយ	ណាក់	អត្តលេខ ០៤៩១
២៨- លោកវរសេនីយ៍ឯក	ម៉ាន់	ឈឿន	អត្តលេខ ០៣៨២៣
២៩- លោកស្រីវរសេនីយ៍ឯក	យូ	ប៉ូលីន	អត្តលេខ ០៥៧៥៣
៣០- លោកវរសេនីយ៍ឯក	ជុំ	ថានី	អត្តលេខ ០១៧៣៨
៣១- លោកវរសេនីយ៍ឯក	ភឹង	ចិន្តាឫទ្ធិ	អត្តលេខ ០៣៦៧១
៣២- លោកស្រីវរសេនីយ៍ឯក	សុខ	សំ	អត្តលេខ ០២៦៣១
៣៣- លោកស្រីវរសេនីយ៍ឯក	ណា	នាង	អត្តលេខ ៦៨២៤៩
៣៤- លោកស្រីវរសេនីយ៍ឯក	ប៉ែន	កញ្ញា	អត្តលេខ ០៨៣៣១

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

៣៥- លោកវរសេនីយ៍ឯក	គិន	សារី	អត្តលេខ ០៥២៩
៣៦- លោកវរសេនីយ៍ឯក	ជិន	សុខុម	អត្តលេខ ១៣២៣០
៣៧- លោកស្រីវរសេនីយ៍ទោ	អៀម	វណ្ណី	អត្តលេខ ១១៤១៥
៣៨- លោកវរសេនីយ៍ទោ	គីម	ឈីន	អត្តលេខ ០៣២៣១
៣៩- លោកវរសេនីយ៍ទោ	ស៊ីន	ចំណាន	អត្តលេខ ០៧៩៩៥
៤០- លោកវរសេនីយ៍ទោ	ម៉ុល	រិទ្ធិ	អត្តលេខ ២០៣៧៨
៤១- លោកវរសេនីយ៍ទោ	ឡាក់	ម៉ុន	អត្តលេខ ០៦០៥៦
៤២- លោកស្រីវរសេនីយ៍ទោ	ប៉ា	សំភារី	អត្តលេខ ២០៣៧៩

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស.រកត-០៨១២.៧៧៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១២

លេខ: ៧៤៣ ច.ល

ថតចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ២០១២

[illegible]រាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧៦៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី២២ ខែ ឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានដំឡើងឋានន្តរស័ក្តិជូននាយនគរបាលជាតិជាន់ខ្ពស់ចំនួន ០៥រូប នៃក្រសួងមហាផ្ទៃ ÷

ក-ថ្នាក់ឧត្តមសេនីយ៍ទោ

១-លោកឧត្តមសេនីយ៍ត្រី **ថោង សុគន្ធា** អត្តលេខ ០១០៨៩

ខ-ថ្នាក់ឧត្តមសេនីយ៍ត្រី

១-លោកវរសេនីយ៍ឯក **ខៀវ សុជាតិ** អត្តលេខ ០២២៤០
២-លោកវរសេនីយ៍ឯក **សយ សាវ៉ាត់** អត្តលេខ ០១២០៧
៣-លោកវរសេនីយ៍ឯក **នួច នេង** អត្តលេខ ០២៣០៧
៤-លោកវរសេនីយ៍ឯក **ម៉ែន ដារី** អត្តលេខ ១២៩៩២

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ចករ
នរោត្តម សីហមុនី

លេខ: ៧៤០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២
[illegible]ទីស្តីការគណៈរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការរាជរដ្ឋាភិបាល
[illegible]យ សុខា

៣រល.១២០៧.៧៧៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧៦៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ត្រាស់បង្គាប់

តែងតាំង :

លោក គួយ សុខចន់

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣១៨.១២០៩.៧៧៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១២

លេខ: ៧៣៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ២០១២
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧៦៩

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម មុត ខៀវ

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រលៈ១២០៥.៧៧៦

លេខៈ ៧៣៤ ប.ល
ដើម្បីចម្លងចែក

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១២

រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្ដីការរាជរដ្ឋាភិបាល

[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧៦០

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ទោ **ទឹម សុផា** អត្តលេខ ០៦០៧ នាយនគរបាលជាតិជាន់ខ្ពស់ ជាទីប្រឹក្សា ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូនលោកឧត្តមសេនីយ៍ទោ **ទឹម សុផា** អត្តលេខ ០៦០៧ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

មាត្រា ៣ : សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុក អនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ដលេខាតទៅ ។

ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចារទ. ១២០៤.៧៧៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២

លេខៈ ៧៤៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្ដីការរាជរដ្ឋាភិបាល
ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៦៦១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** ជូនលោកឧត្តមសេនីយ៍ត្រី **យស់ ផន** អត្តលេខ ០៥៨៩ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុក អនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពាកស.១២០៥.៦៦៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១២

លេខ: ៧៤៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ២០១២
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧៧៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដំឡើងឋានៈ ឯកឧត្តមអគ្គលេខាធិការរងរាជរដ្ឋាភិបាល ៖

- ឯកឧត្តម **ទ៉ាន់ ផល** អគ្គលេខាធិការរងរាជរដ្ឋាភិបាល មានឋានៈស្មើ រដ្ឋលេខាធិការ
- ឯកឧត្តម **ហេង សិរីភា** អគ្គលេខាធិការរងរាជរដ្ឋាភិបាល មានឋានៈស្មើ រដ្ឋលេខាធិការ

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខៈ៧ ៤៧ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១២
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊យ សុខា

៣១ស.១២០៥.៧៥២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៥៦ ខែ សីហា ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧៦៧៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការ និងសប្បុរសជន ចំនួន ២៨រូប ដែលមានគុណបំណាច់យ៉ាងធំធេងក្នុងការបម្រើជាតិមាតុភូមិ

នូវ

ក- គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- ឯកឧត្តម តែន សម្បត្តិ

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១- ឯកឧត្តមឧកញ៉ា លឹម ហុងឈាង
២- ឯកឧត្តម ម៉ី ឧត្តម
៣- លោកជំទាវ ត្រុំ នីដា

គ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១- លោក គៀ សុវណ្ណ
២- លោក ផាន់ គីមសន
៣- លោក ខ៊ូ វណ្ណា
៤- លោក នី ស៊ីចន្ថា
៥- លោក តើត តារាស៊ី
៦- លោក សួរ ណាល់
៧- លោក ឈន ហួរ

ឃ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

១- លោក ឆេព ទីរម
២- លោក មាស មារីន
៣- លោក សេង សារី
៤- លោក គង់ មនោ
៥- លោក គួច យាន
៦- លោក ម៉ាន់ សិទ្ធី
៧- លោក តាត ចន
៨- លោកស្រី ហួត យ៉ាន
៩- លោក ចាន់ ចាសនា
១០- លោក ប៊ិច សុធី
១១- លោក កែវ នរាធី
១២- លោក អោម មន្នីវណ្ណ
១៣- លោក អ៊ុន សុផានណារិទ្ធ

ង- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :

១- លោក ជ័យ ឌឹម
២- លោក ហែម យៀត
៣- លោក ព្រុំ ផ
៤-លោក ហែម យែត

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៦ស.១២០៧.៣៥៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១២

លេខ [illegible] ច.ល
ដើម្បីចម្លងទុក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២
[illegible]
[illegible] សុខា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៣៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកែសម្រួលគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៥ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

សម្រេច
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ត្រូវបានកែសម្រួលគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា ដែលសរសេរជាអក្សរកាត់ថា **គ.ក.ប.** ជាយន្តការដោះស្រាយនិងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលលើការដោះស្រាយបញ្ហាកូដកម្ម បាតុកម្មគ្រប់មុខសញ្ញា។

ជំពូកទី២
សមាសភាព

មាត្រា ២.-

គ.ក.ប. មានសមាសភាពដូចតទៅ៖

- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រធាន
- រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុប្រធាន
- រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម អនុប្រធាន
- រដ្ឋលេខាធិការក្រសួងការពារជាតិ អនុប្រធាន
- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន
- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន
- អគ្គស្នងការនគរបាលជាតិ អនុប្រធាន
- មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស អនុប្រធាន
- អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ អនុប្រធាន
- នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី អនុប្រធាន
- រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អនុប្រធានប្រចាំការ
- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
- រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក
- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា សមាជិក
- រដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក
- រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា សមាជិក
- រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
- អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក
- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក
- អភិបាលនៃគណៈអភិបាលខេត្តកណ្តាល សមាជិក
- ប្រធាននាយកដ្ឋានស្រាវជ្រាវ ចារកិច្ច អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ សមាជិក
- ប្រធានការិយាល័យទី២ កងទ័ពជើងគោក សមាជិក
- មេធាវីរាជរដ្ឋាភិបាល សមាជិក
- សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- ទីប្រឹក្សាក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

- អគ្គាធិការនៃអគ្គាធិការដ្ឋាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក
- ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម សមាជិក
- ប្រធានសេនាធិការដ្ឋាន អគ្គស្នងការនគរបាលជាតិនៃក្រសួងមហាផ្ទៃ សមាជិក
- ប្រធាននាយកដ្ឋានសន្តិសុខផ្ទៃក្នុង អគ្គស្នងការនគរបាលជាតិនៃក្រសួងមហាផ្ទៃ សមាជិក
- ប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ អគ្គស្នងការនគរបាលជាតិនៃក្រសួងមហាផ្ទៃ សមាជិក
- ប្រធានអង្គភាពអន្តរាគមន៍ អគ្គស្នងការនគរបាលជាតិនៃក្រសួងមហាផ្ទៃ សមាជិក
- ប្រធាននាយកដ្ឋានចារកម្ម អគ្គស្នងការនគរបាលជាតិនៃក្រសួងមហាផ្ទៃ សមាជិក
- ប្រធាននាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
- ប្រធាននាយកដ្ឋានវិវាទការងារនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
- នាយកបេឡាជាតិរបបសន្តិសុខសង្គមនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
- អភិបាលនៃគណៈអភិបាលខេត្ត សមាជិក
- អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ក.ប.** សមាជិកប្រចាំការ។

សមាសភាពជាក់ស្តែងរបស់ **គ.ក.ប.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

ជំពូកទី៣
តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

មាត្រា ៣.-

គ.ក.ប. មានតួនាទីនិងភារកិច្ចដូចតទៅៈ

- តាមដាន ប្រមូលព័ត៌មាន លើកវិធានការទប់ស្កាត់ និងធ្វើអន្តរាគមន៍ដោះស្រាយតាមផ្លូវច្បាប់នូវរាល់បញ្ហាកូដកម្ម បាតុកម្មដែលកើតមានឡើងនៅគ្រប់មុខសញ្ញា
- ណែនាំគោលការណ៍ វិធានការដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម ដល់គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត
- ធ្វើរបាយការណ៍និងលើកសំណើជូនរាជរដ្ឋាភិបាលសុំវិធានការដោះស្រាយ
- សហការជាមួយអង្គការដៃគូពាក់ព័ន្ធ និយោជក សហជីព សង្គមស៊ីវិល ដើម្បីអភិវឌ្ឍសុខដុមនីយកម្មសង្គម និងការទំនាក់ទំនងវិជ្ជាជីវៈ
- ចុះដោះស្រាយករណីកូដកម្ម បាតុកម្ម ដល់មូលដ្ឋានជាក់ស្តែងតាមការចាំបាច់
- ដោះស្រាយករណីពេងចក្រដួលរលំដោយវិបត្តិផ្សេងៗ និងហានិភ័យជាយថាហេតុ
- ធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ៩ខែ និងប្រចាំឆ្នាំ
- បំពេញភារកិច្ចផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

មាត្រា ៤.-

គ.ក.ប. មានអគ្គលេខាធិការដ្ឋានមួយជាអង្គភាពប្រតិបត្តិ ដែលមានទីតាំងនៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

មាត្រា ៥.-

អគ្គលេខាធិការដ្ឋាន **គ.ក.ប.** មានតួនាទីនិងភារកិច្ចដូចតទៅៈ

- រៀបចំនិងអនុវត្តផែនការសកម្មភាពការងាររយៈពេលខ្លី មធ្យម និងវែងដែលពាក់ព័ន្ធនឹងការទប់ស្កាត់បញ្ហាកូដកម្ម បាតុកម្ម ជូន **គ.ក.ប**./

- ពិនិត្យ តាមដានស្ថានភាពនៃបញ្ហាកូដកម្ម បាតុកម្ម និងលើកអនុសាសន៍ដោយផ្អែកលើគោលការណ៍ច្បាប់ជូន **គ.ភ.ម.**

- សិក្សាស្រាវជ្រាវច្បាប់ជាតិ អន្តរជាតិ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងបញ្ហាកូដកម្ម បាតុកម្ម ដើម្បីលើកអនុសាសន៍ជូន **គ.ភ.ម.**

- ធានានិរន្តរភាពនិងដំណើរការរដ្ឋបាលរបស់ **គ.ភ.ម.**

- គ្រប់គ្រងមន្ត្រីអគ្គលេខាធិការដ្ឋាន **គ.ភ.ម.**

- លើកសំណើតែងតាំង ផ្ទេរភារកិច្ច បញ្ឈប់ពីតំណែង និងជ្រើសរើសមន្ត្រីរាជការ ទីប្រឹក្សា និងបុគ្គលិកជាប់កិច្ចសន្យាក្នុងអគ្គលេខាធិការដ្ឋាន

- លើកគម្រោងថវិកាប្រចាំឆ្នាំសម្រាប់កិច្ចដំណើរការ **គ.ភ.ម.**

- គ្រប់គ្រងអនុវត្តចំណូល ចំណាយថវិកា និងបញ្ជីសារពើភណ្ឌចលនទ្រព្យ អចលនទ្រព្យរបស់ **គ.ភ.ម.**

- រៀបចំសិក្ខាសាលានិងកិច្ចប្រជុំផ្សេងៗរបស់ **គ.ភ.ម.**

- ចងក្រងព័ត៌មាននិងឯកសារដែលពាក់ព័ន្ធនឹងបញ្ហាកូដកម្ម បាតុកម្ម

- សហការជាមួយអង្គការដៃគូពាក់ព័ន្ធ និយោជក សហជីព សង្គមស៊ីវិល ដើម្បីអភិវឌ្ឍសុខដុមនីយកម្មសង្គម និងការទំនាក់ទំនងវិជ្ជាជីវៈ

- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ៩ខែនិងប្រចាំឆ្នាំ ស្តីពីសកម្មភាពការងាររបស់ **គ.ភ.ម.**

- បំពេញភារកិច្ចផ្សេងៗទៀតដែលប្រធាន **គ.ភ.ម.** ប្រគល់ជូន។

មាត្រា ៦.-

អគ្គលេខាធិការដ្ឋាន **គ.ភ.ម.** ដឹកនាំដោយអគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរងមួយចំនួន ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យឬអនុក្រឹត្យ។

មាត្រា ៧.-

អគ្គលេខាធិការដ្ឋាន **គ.ភ.ម.** មានរចនាសម្ព័ន្ធដូចតទៅ៖

- ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងបូកសរុប
- ផ្នែកស្រាវជ្រាវព័ត៌មាន បណ្តុះបណ្តាល និងចលនាមហាជន
- ផ្នែកអន្តរាគមន៍និងដោះស្រាយ
- ផ្នែកសុខដុមនីយកម្មសង្គមនិងទំនាក់ទំនងវិជ្ជាជីវៈ
- ផ្នែកគតិយុត្ត។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន **គ.ភ.ម.** មានភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា ៨.-

ផ្នែកនីមួយៗត្រូវដឹកនាំដោយប្រធានផ្នែកមួយរូប អមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។ ប្រធានផ្នែកមានឋានៈស្មើប្រធាននាយកដ្ឋាន និងអនុប្រធានផ្នែកមានឋានៈស្មើអនុប្រធាននាយកដ្ឋាន។

ផ្នែកនីមួយៗមានការិយាល័យចំណុះតាមការចាំបាច់។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះផ្នែកនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។/.

មាត្រា ៩.-

អគ្គលេខាធិការដ្ឋាន **គ.ភ.ប.** មានមន្ត្រីបម្រើការងារមកពីក្របខ័ណ្ឌមុខងារសាធារណៈ។ ក្នុងករណីចាំបាច់ អគ្គលេខាធិការដ្ឋានអាចមានមន្ត្រីជាប់កិច្ចសន្យាដើម្បីជួយបំពេញការងារ។

មាត្រា ១០.-

ត្រូវបង្កើតគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញានៅតាមរាជធានី ខេត្ត ខណ្ឌ ក្រុង ស្រុក ឃុំ សង្កាត់។

សមាសភាព ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា នៅតាមរាជធានី ខេត្ត ខណ្ឌ ក្រុង ស្រុក ឃុំ សង្កាត់ ត្រូវកំណត់ដោយដីការបស់រាជធានី ខេត្ត។

មាត្រា ១១.-

គណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមរាជធានី ខេត្ត ខណ្ឌ ក្រុង ស្រុក ឃុំ សង្កាត់ ត្រូវទទួលខុសត្រូវដោះស្រាយរាល់បញ្ហាកូដកម្ម បាតុកម្មដែលពាក់ព័ន្ធ ដើម្បីទប់ស្កាត់និងដោះស្រាយរាល់ករណីកូដកម្ម បាតុកម្ម ឲ្យមានប្រសិទ្ធភាពនិងទាន់ពេលវេលា។

ជំពូកទី៤
តួនាទីនិងភារកិច្ចរបស់ផ្នែកនីមួយៗ

មាត្រា ១២.-

ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងបូកសរុប មានតួនាទីនិងភារកិច្ចដូចតទៅៈ

- អនុវត្តការងាររដ្ឋបាលប្រចាំថ្ងៃរបស់អគ្គលេខាធិការដ្ឋាន
- រៀបចំលិខិតរដ្ឋបាល ធ្វើកំណត់ហេតុរាល់កិច្ចប្រជុំរបស់ **គ.ភ.ប.**
- គ្រប់គ្រងមន្ត្រី បុគ្គលិក និងឯកសាររដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន
- រៀបចំគម្រោងថវិកានិងគម្រោងផ្សេងៗទៀត
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ និងបញ្ជីសារពើភណ្ឌរបស់អគ្គលេខាធិការដ្ឋាន
- គ្រប់គ្រងចំណូលនិងចំណាយរបស់អគ្គលេខាធិការដ្ឋាន
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ **គ.ភ.ប.** ប្រគល់ជូន។

មាត្រា ១៣.-

ផ្នែកស្រាវជ្រាវព័ត៌មាន បណ្តុះបណ្តាល និងចលនាមហាជន មានតួនាទីនិងភារកិច្ចដូចតទៅៈ

- ប្រមូលព័ត៌មានអំពីប្រភព មូលហេតុ មុខសញ្ញា ដែលប៉ុនប៉ងបង្កឲ្យមានបញ្ហាកូដកម្ម បាតុកម្ម
- គ្រប់គ្រងសមាសភាព អង្គភាពមូលដ្ឋាន ដែលអាចបង្កឲ្យមានបញ្ហាកូដកម្ម បាតុកម្ម
- លើកអនុសាសន៍ វិធានការទប់ស្កាត់ បញ្ហាកូដកម្ម បាតុកម្ម
- រៀបចំខ្លឹមសារនិងកម្មវិធីបណ្តុះបណ្តាលមន្ត្រីពាក់ព័ន្ធ ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម
- រៀបចំខ្លឹមសារ ឃោសនាផ្សព្វផ្សាយ អប់រំ ទប់ស្កាត់ ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម

- ផ្តល់ព័ត៌មានជូនសាធារណជន អំពីការដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម
- ទំនាក់ទំនងជាមួយអង្គការជាតិនិងអន្តរជាតិ និយោជក សហជីព សង្គមស៊ីវិលពាក់ព័ន្ធ ដើម្បីសម្របសម្រួលដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម
- ចាត់វិធានការឃោសនាផ្ទាល់មាត់ និងបណ្តាញឃោសនិកចូលរួមក្នុងការទប់ស្កាត់ ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ **គ.ក.ប.** ប្រគល់ជូន។

មាត្រា ១៤.-

ផ្នែកអន្តរាគមន៍និងដោះស្រាយ មានតួនាទីនិងភារកិច្ចដូចតទៅ៖
- រៀបចំក្រុមអន្តរាគមន៍ ចុះដោះស្រាយករណីកូដកម្ម បាតុកម្មដល់ទីកន្លែង
- តាមដាន ផ្តល់យោបល់ជូនគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា នៅតាមរាជធានី ខេត្ត ខណ្ឌ ក្រុង ស្រុក ឃុំ សង្កាត់ អំពីការដោះស្រាយករណីកូដកម្ម បាតុកម្ម
- ចាត់វិធានការឲ្យគ្រប់ភាគីពាក់ព័ន្ធ ចូលរួមក្នុងការចរចា ដោះស្រាយរាល់ករណីកូដកម្ម បាតុកម្ម
- កោះអញ្ជើញភាគីពាក់ព័ន្ធ ដើម្បីធ្វើការដោះស្រាយនៅថ្នាក់ **គ.ក.ប.**
- សហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ អន្តរាគមន៍ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម
- លើកយោបល់ជូនអគ្គលេខាធិការ **គ.ក.ប.** ដើម្បីចាត់វិធានការដោះស្រាយចំពោះករណីដែលចាំបាច់
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ **គ.ក.ប.** ប្រគល់ជូន។

មាត្រា ១៥.-

ផ្នែកសុខដុមនីយកម្មសង្គមនិងទំនាក់ទំនងវិជ្ជាជីវៈ មានតួនាទីនិងភារកិច្ចដូចតទៅ៖
- ធ្វើជាលេខាធិការដ្ឋានឲ្យក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ
- ទំនាក់ទំនងជាមួយនិយោជក សហជីព អង្គការពលកម្មអន្តរជាតិ អង្គការជាតិ និងអន្តរជាតិពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាដែលទាក់ទងនឹងការសម្របសម្រួលទំនាក់ទំនងវិជ្ជាជីវៈ
- តាមដាន ប្រមូលព័ត៌មាន និងលើកអនុសាសន៍សម្របសម្រួលទំនាក់ទំនងវិជ្ជាជីវៈ
- រៀបចំការប្រជុំ ធ្វើកំណត់ហេតុ របាយការណ៍របស់ក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ
- សិក្សាស្រាវជ្រាវការអភិវឌ្ឍវិស័យទំនាក់ទំនងវិជ្ជាជីវៈ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ **គ.ក.ប.** ប្រគល់ជូន។

មាត្រា ១៦.-

ផ្នែកគតិយុត្ត មានតួនាទីនិងភារកិច្ចដូចតទៅ៖
- សិក្សាស្រាវជ្រាវច្បាប់ជាតិនិងអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ
- រៀបចំគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម
- លើកវិធានការតាមផ្លូវច្បាប់សម្រាប់ដោះស្រាយករណីកូដកម្ម បាតុកម្ម

- ចូលរួមក្នុងការដោះស្រាយករណីក្ងដកម្ម បាតុកម្ម តាមមូលដ្ឋានជាក់ស្ដែង
- រៀបចំពាក្យបណ្ដឹងទៅស្ថាប័នតុលាការដើម្បីដោះស្រាយក្ងដកម្ម បាតុកម្ម តាមនីតិវិធីច្បាប់
- ជាតំណាងឲ្យ **គ.ភ.ម**. តាមការប្រគល់សិទ្ធិ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ **គ.ភ.ម**. ប្រគល់ជូន។

ជំពូកទី៥
របៀបរបបធ្វើការរបស់ គ.ភ.ម.

មាត្រា ១៧.-

គ.ភ.ម. ត្រូវជួបប្រជុំវាយតម្លៃបូកសរុបការងារយ៉ាងតិច២(ពីរ)ដងក្នុងមួយឆ្នាំ។ ក្នុងករណីចាំបាច់ **គ.ភ.ម**. អាចប្រជុំជាវិសាមញ្ញបាន តាមការអញ្ជើញរបស់ប្រធាន។

មាត្រា ១៨.-

គ.ភ.ម. មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

ជំពូកទី៦
ប្រភពធនធាន

មាត្រា ១៩.-

គ.ភ.ម. មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

គ.ភ.ម. មានសិទ្ធិទទួលនិងគ្រប់គ្រងមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ និងពីប្រភពផ្សេងៗទៀតសម្រាប់បំពេញការងាររបស់ខ្លួន។

មាត្រា ២០.-

គណៈកម្មការសម្រាប់ដោះស្រាយបញ្ហាក្ងដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា នៅតាមរាជធានី ខេត្ត ខណ្ឌ ក្រុង ស្រុក ឃុំ សង្កាត់ ត្រូវមានមធ្យោបាយសម្រាប់ប្រើប្រាស់ និងថវិកាដែលត្រូវដាក់បញ្ចូលក្នុងកញ្ចប់ថវិកានៃរាជធានី ខេត្ត ខណ្ឌ ក្រុង ស្រុក ឃុំ សង្កាត់។

គណៈកម្មការសម្រាប់ដោះស្រាយបញ្ហាក្ងដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា នៅតាមរាជធានី ខេត្ត ខណ្ឌ ក្រុង ស្រុក ឃុំ សង្កាត់ មានសិទ្ធិទទួលនិងគ្រប់គ្រងមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ និងពីប្រភពផ្សេងៗទៀតសម្រាប់បំពេញការងាររបស់ខ្លួន។

ជំពូកទី៧
អន្តរប្បញ្ញត្តិ

មាត្រា ២១.-

ក្រោយអនុក្រឹត្យនេះចូលជាធរមាន លិខិតបទដ្ឋានដែលមានមុន ត្រូវបន្តអនុវត្តរហូតដល់មានលិខិតបទដ្ឋានថ្មីមកជំនួស។

ជំពូកទី៨
អវសានប្បញ្ញត្តិ

មាត្រា ២២.-

សេចក្តីសម្រេចលេខ៣២ សសរ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៨ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា ២៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
ដើម្បីគោរពស្នើសុំហត្ថលេខា

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

អ៊ិត សំហេង

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៣៦. អនក្រ.បក ចុះថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការកែសម្រួលគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :១៣៧...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥, ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០១៩, ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១២

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក, ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក, ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ២៨៧ អនក្រ.បក, ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១១ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១២

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

មាត្រា១:ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកាចំនួន៣ ២០០ ០០០ ០០០រៀល(បីពាន់ពីររយលានរៀលគត់) ពីជំពូក០៩(ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក៦៥(ឧបត្ថម្ភកធននិងជំនួយសង្គម) ជូនទីស្តីការគណៈរដ្ឋមន្ត្រីសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២។

មាត្រា២:ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីផ្តល់ជូនៈ

- អាជ្ញាធរ NIDA ចំនួន ៣០០ ០០០ ០០០ រៀល
- អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស ចំនួន ៣០០ ០០០ ០០០ រៀល
- ក្រុមប្រឹក្សាជាតិភាសាខ្មែរ ចំនួន ១០០ ០០០ ០០០ រៀល
- គណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ ចំនួន ២០០ ០០០ ០០០ រៀល
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ចំនួន ២០០ ០០០ ០០០ រៀល
- កាយរឹទ្ធិកម្ពុជា ចំនួន ៤០០ ០០០ ០០០ រៀល
- រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ចំនួន ៨០០ ០០០ ០០០ រៀល
- គណៈកម្មាធិការជាតិអេស្កាប់ ចំនួន ២០០ ០០០ ០០០ រៀល
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ចំនួន ៤០០ ០០០ ០០០ រៀល
- ក្រុមប្រឹក្សាភិបាលមជ្ឈមណ្ឌលសកម្មភាពកំចាត់មីន ចំនួន ១០០ ០០០ ០០០ រៀល
- គណៈវិស្វករកម្ពុជា ចំនួន ២០០ ០០០ ០០០ រៀល

សម្រាប់ចំណាយដំណើរការបន្តរហូតដល់ដំណាច់ឆ្នាំ២០១២។

មាត្រា៣:រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៣៨ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការទទួលស្គាល់ការប្រែក្លាយពី វិទ្យាស្ថាន ប៊ែលធី អន្តរជាតិ ទៅជា សាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអប់រំ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

-បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ

-បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៥ ស្តីពីការប្តូរឈ្មោះ " វិទ្យាស្ថានអាស៊ីប៉ាស៊ីភិច ទៅជា វិទ្យាស្ថាន ប៊ែលធី អន្តរជាតិ "

-តាមសំណើរបស់ក្រសួងអប់រំ យុវជន និង កីឡា

សម្រេច

មាត្រា ១ ៖ ទទួលស្គាល់ការប្រែក្លាយពី វិទ្យាស្ថាន ប៊ែលធី អន្តរជាតិ (BELTEI International Institute) ទៅជា **សាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ** (BELTEI International University) សរសេរកាត់ជាភាសាខ្មែរ " **ស.ប.អ.** " និង សរសេរកាត់ជាភាសាអង់គ្លេស " BIU "។

មាត្រា ២ ៖ សាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ មានទីតាំងឋិតនៅដីឡូត៍លេខ ២១ ផ្លូវលេខ៣៦០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ និង ឋិតនៅក្រោមឱវាទក្រសួងអប់រំ យុវជន និង កីឡា។

មាត្រា ៣ ៖ សាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រ និង បរិញ្ញាបត្រជាន់ខ្ពស់ លើមហាវិទ្យាល័យប្រាំមួយ និង វិទ្យាស្ថានមួយ ៖

-មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម

-មហាវិទ្យាល័យអប់រំ សិល្បៈ និង មនុស្សសាស្ត្រ

-មហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសង្គម

-មហាវិទ្យាល័យទេសចរណ៍ និង បដិសណ្ឋារកិច្ច

-មហាវិទ្យាល័យវិស្វកម្ម និង ស្ថាបត្យកម្ម

-មហាវិទ្យាល័យព័ត៌មានវិទ្យា និង វិទ្យាសាស្ត្រ

-វិទ្យាស្ថាន ប៊ែលធី អន្តរជាតិ

ទៅអនាគត សាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ ត្រូវរៀបចំកម្មវិធីសិក្សាលម្អិត តាមកម្រិត និង មុខជំនាញ ដើម្បីសុំការឯកភាពពី ក្រសួងអប់រំ យុវជន និង កីឡា។ សាកលវិទ្យាល័យនេះ អាចបើកសាខា មហាវិទ្យាល័យថ្មី មុខជំនាញថ្មី កម្រិតថ្មី ឬ ថ្នាក់ថ្មី ប្រភេទបណ្តុះបណ្តាលថ្មី ប្តូរឈ្មោះថ្មី ឬ ទីតាំងថ្មី ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និង កីឡា។

មាត្រា ៤ ៖ សាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ ត្រូវរៀបចំក្រុមប្រឹក្សាភិបាលមួយ ដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និង កីឡា ដើម្បីពិនិត្យ និង សម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និង ការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។

មាត្រា ៥ ៖ សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ មានភារកិច្ច ៖

-ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ និង ធានាឱ្យមានសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម

-ទទួលខុសត្រូវក្នុងការជ្រើសរើសនិស្សិតឱ្យចូលរៀន និង ទទួលនិស្សិតឱ្យសិក្សាបន្ត តាមកម្មវិធីសិក្សារបស់ សាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ

-អនុវត្តតាមបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និង កីឡា ដែលកំណត់លើសកម្មភាពនៃការធានាគុណភាពអប់រំ

-រៀបចំតួនាទី ភារកិច្ច និង រចនាសម្ព័ន្ធគ្រប់គ្រងសាកលវិទ្យាល័យ និង បទប្បញ្ញត្តិសម្រាប់ការគ្រប់គ្រងការសិក្សា ឲ្យបានច្បាស់លាស់

-ធ្វើរបាយការណ៍ជូនក្រសួងអប់រំ យុវជន និង កីឡា តាមការកំណត់។

មាត្រា ៦ ៖ និស្សិតសាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ ដែលបានរៀនចប់កម្មវិធីសិក្សា និង ទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និង មុខជំនាញ ដែលបានសិក្សា។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយសាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និង កីឡា ក្នុងករណីសាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ បំពេញ និង អនុវត្តបាន តាមគោលការណ៍ និង បទដ្ឋានរបស់ក្រសួងអប់រំ យុវជន និង កីឡា។

មាត្រា ៧ ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ប្រធានស្ថាប័នពាក់ព័ន្ធ និង ក្រុមប្រឹក្សាភិបាល រួមជាមួយ សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-សាលារាជធានីភ្នំពេញ
-រាជកិច្ច
-ដូចមាត្រា ៧ " ដើម្បីអនុវត្ត "
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ១៣៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកែសម្រួលមាត្រា ៤ និងមាត្រា ១៣ នៃអនុក្រឹត្យលេខ ១២១ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់មជ្ឈមណ្ឌលជាតិ គ្រប់គ្រងកងកម្លាំង រក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងការពារជាតិ
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ១៣ សសរ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលគណៈកម្មាធិការជាតិ សម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្ម រក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការកែសម្រួល និងតម្លើងមជ្ឈមណ្ឌលបោសសំអាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងបណ្តុះបណ្តាល
- បានឃើញអនុក្រឹត្យលេខ ១២១ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់មជ្ឈមណ្ឌលជាតិ គ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា មួយ.-

ត្រូវបានកែសម្រួលមាត្រា ៤ និងមាត្រា ១៣ នៃអនុក្រឹត្យលេខ ១២១ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់មជ្ឈមណ្ឌលជាតិ គ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម ដូចតទៅៈ

មាត្រា ៤ ថ្មី.-

ម.ជ.រ.ប.ក មានរចនាសម្ព័ន្ធដូចខាងក្រោមៈ

- លេខាធិការដ្ឋាន
- ជំនាញគ្រប់គ្រង ធនធានមនុស្ស និងបណ្តុះបណ្តាល
- ជំនាញគ្រប់គ្រង ភស្តុភារ ហិរញ្ញវត្ថុ និងសុខាភិបាល

- ជំនាញគ្រប់គ្រង ស្តង់ដាសម្ភារៈ និងបច្ចេកទេស
- នាយកដ្ឋានស្រាវជ្រាវ ទិន្នន័យ និងវិស្វកម្ម
- នាយកដ្ឋានកាកសំណល់សង្គ្រាម គ្រឿងផ្ទុះ និងព័ត៌មាន
- នាយកដ្ឋានទំនាក់ទំនង សហប្រតិបត្តិការ រក្សាសន្តិភាព និងនីតិកម្ម
- វិទ្យាស្ថានហ្វឹកហ្វឺនបណ្តុះបណ្តាល កងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម
- សាលាហ្វឹកហ្វឺនកងកម្លាំងរក្សាសន្តិភាពពហុជាតិ ហៅកាត់ថា ស.ហ.ក.រ.ស.ព ជាភាសាអង់គ្លេសសរសេរថា Training School for Multinational Peace Keeping Operation ហៅកាត់ថា TSMPKO ។

អង្គការលេខ នៃ ម.ជ.រ.ប.ក ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

មាត្រា ១៣ ថ្មី.-

វិទ្យាស្ថានហ្វឹកហ្វឺនបណ្តុះបណ្តាលកងកម្លាំង រក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម និងសាលាហ្វឹកហ្វឺនកងកម្លាំងរក្សាសន្តិភាពពហុជាតិ នៃមជ្ឈមណ្ឌលជាតិគ្រប់គ្រង កងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម មានភារកិច្ចដូចតទៅ៖

ក/-ភារកិច្ចរបស់វិទ្យាស្ថានហ្វឹកហ្វឺនបណ្តុះបណ្តាលកងកម្លាំង រក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម មានដូចខាងក្រោម៖

- រៀបចំផែនការ និងហ្វឹកហ្វឺនបណ្តុះបណ្តាលគ្រប់ជំនាញ ក្នុងរយៈពេលវែង មធ្យម ខ្លី ស្របតាមស្តង់ដាជាតិ អន្តរជាតិ
- សិក្សា ស្រាវជ្រាវ និងដកបទពិសោធន៍ នូវការអនុវត្តថ្មីៗ ដែលសមស្របតាមស្តង់ដា អង្គការសហប្រជាជាតិ
- ហ្វឹកហ្វឺនសិក្ខាកាមជាតិ និងអន្តរជាតិ ផ្នែករក្សាសន្តិភាព ផ្នែកបោសសំអាតមីន ផ្នែកកំទេចគ្រឿងផ្ទុះ ផ្នែកវិស្វកម្ម មានវិស្វករសំណង់បញ្ស្ប ផ្នែក ជម្រកសុវត្ថិភាព ផ្នែកភាសាបរទេស និងសង្កេតការណ៍យោធា-ស៊ីវិល
- ធ្វើទស្សនកិច្ចសិក្សាស្វែងយល់ ទំនាក់ទំនង ដកស្រង់បទពិសោធន៍ ជាមួយបណ្តា វិទ្យាស្ថាន សាលាហ្វឹកហ្វឺន ស្ថាប័ន និងអង្គភាពនានា ក្នុង និងក្រៅប្រទេស
- វាយតម្លៃការសិក្សារបស់សិក្ខាកាមក្រោយបញ្ចប់វគ្គសិក្សានីមួយៗ ដើម្បីជ្រើសរើសសិក្ខាកាម ដែលមានពិន្ទុល្អៗ ធ្វើជាអ្នកផ្តល់បទពិសោធន៍ដល់សិក្ខាកាម ដែលមិនទាន់មានសមត្ថភាពគ្រប់គ្រាន់
- សហការជាមួយក្រសួង ស្ថាប័ននានា បណ្តាប្រទេសជាដៃគូ និងអង្គការសហប្រជាជាតិ ស្វែងរកគ្រូយោធាចារ្យ មន្ត្រីជំនាញជាតិ-អន្តរជាតិ និងអង្គការសហប្រជាជាតិល្អៗ សម្រាប់មកហ្វឹកហ្វឺនបណ្តុះបណ្តាលដល់កងកម្លាំងពហុជាតិ
